**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

៚៙៚ ❖ ៚៙៚

**ក្រសួងអប់រំ យុវជន និងកីឡា**

**លេខ : ៧០១ អយក.ប្រក**

# ប្រកាស

ស្តីពី ការបើកសាលាបឋមសិក្សា **លៀប**

ជាឧបសម្ព័ន្ធរបស់សាលាបឋមសិក្សា **ត្រពាំងសាលា**

---

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

-បានឃើញព្រះរាជក្រឹត្យលេខនស-រកត ១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា

-បានឃើញអនុក្រឹត្យលេខ២១អនក្រ.ប.កចុះថ្ងៃទី២៣ ខែមិនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា

-បានឃើញអនុក្រឹត្យលេខ ១០៤ អនក្រ-បក ចុះថ្ងៃទី១៤ ខែ តុលា ឆ្នាំ ២០០២ ស្តីពីការកែសំរួលរចនាសម្ព័ន្ធនាយកដ្ឋានបឋមនិងមត្តេយ្យសិក្សា ជានាយកដ្ឋានបឋមសិក្សា និង នាយកដ្ឋានអប់រំកុមារតូច

-បានពិនិត្យលិខិតរបស់គណៈកម្មការទ្រទ្រង់សាលាបឋមសិក្សា **លៀប** ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០០២ ដោយមានចំណារឯកភាព របស់មន្ទីរ អប់រំយុវជន និង កីឡា ខេត្ត **កំពត** ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០០២

-តាមយោបល់ឯកភាពរបស់ **នាយកដ្ឋានបឋមសិក្សា**

## ស ម្រេ ច

**ប្រការ១** : បើកសាលាបឋមសិក្សា **លៀប** ជាឧបសម្ព័ន្ធរបស់សាលាបឋមសិក្សា **ត្រពាំងសាលា** ដែលមានទីតាំងស្ថិតនៅភូមិ **លៀប** ឃុំ **ត្រពាំងសាលាខាងកើត** ស្រុក **បន្ទាយមាស** ខេត្ត **កំពត** ចាប់ពីឆ្នាំសិក្សា ២០០២-២០០៣ នេះតទៅ ។

**ប្រការ២** : សាលាបឋមសិក្សា **លៀប** ត្រូវមានប្រធានក្រុមម្នាក់ ទទួលខុសត្រូវ រួមជាមួយនាយកសាលាបឋមសិក្សា **ត្រពាំងសាលា** ។

**ប្រការ៣** : អគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានបឋមសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត **កំពត** ការិយាល័យអប់រំ យុវជន និងកីឡាស្រុក **បន្ទាយមាស** នាយកសាលាបឋមសិក្សា **ត្រពាំងសាលា** និង ប្រធានក្រុមសាលាឧបសម្ព័ន្ធ **លៀប** មានភារកិច្ចអនុវត្តប្រកាសនេះ ។

ភ្នំពេញ , ថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០៣

**ជ. រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា**

**រដ្ឋលេខាធិការ**

**អ៊ុំ_សិទ្ធី**

**កន្លែងទទួល**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

-ក្រសួងផែនការ-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-សាលាខេត្ត **កំពត**

"**<u>ដើម្បីជូនជ្រាបជាពត៌មាន</u>**"

-ដូចប្រការ ៣

-កាលប្បវត្តិ-ឯកសារ នា .បស